Disability Rights California
*ប្រព័ន្ធការពារ និងតស៊ូមតិរបស់រដ្ឋកាលីហ្វ័រនីញ៉ា*
*លេខទូរស័ព្ទហៅមិនអស់ប្រាក់ (800) 776-5746*

# កម្មវិធីគាំពារ/ផ្តល់ប្រាក់ឧបត្ថម្ភការងារក្រោមច្បាប់ Title II -SSDI

*ខែមីនា ឆ្នាំ**2016** អត្ថបទបោះពុម្ពផ្សាយលេខ **5522.06 - Cambodian***

## តើខ្ញុំនៅតែអាចទទួលបានអត្ថប្រយោជន៍ SSDI ទេ ពេលខ្ញុំមានការងារធ្វើ?

នេះគឺជាសំណួរមួយដែលអ្នកទទួលអត្ថប្រយោជន៍សន្តិសុខសង្គមផ្នែកធានារ៉ាប់រងពិការភាព (SSDI, Social Security Disability Insurance) តែងចោទសួរជាញឹកញាប់ នៅពេលពួកគេចង់រកការងារធ្វើ ។ រដ្ឋបាលសន្តិសុខសង្គម (SSA, Social Security Administration) មានផ្តល់ជូនកម្មវិធីគាំពារ/ផ្តល់ប្រាក់ឧបត្ថម្ភការងារដែលអ្នកអាចប្រើក្នុងការស្វែងរកការងារ ។

ជំនួយជ្រោមជ្រែងការងារ/ប្រាក់ឧបត្ថម្ភការងារទាំងនេះ អាចជួយឲ្យអ្នកអាចរក្សាទុកបាននូវអត្ថប្រយោជន៍ SSDI និងការធានារ៉ាប់រង Medicare របស់អ្នកក្នុងពេលអ្នកធ្វើការ ។ ខាងក្រោមគឺជាការពិភាក្សាគ្នាមួយស្តីអំពីកម្មវិធីគាំពារ/ផ្តល់ប្រាក់ឧបត្ថម្ភការងារដែលមានផ្តល់ជូនចំពោះអ្នកទទួលអត្ថប្រយោជន៍ SSDI ។

## កម្មវិធីជ្រោមជ្រែងការងារ/ផ្តល់ប្រាក់ឧបត្ថម្ភការងារ SSDI

**អំឡុងពេលសាកល្បងការងារ ៖** យោងទៅតាមក្រមសន្តិសុខសង្គម (Social Security Act, The Act) នៅពេលអ្នកទទួលបានជំនួយ SSDI ហើយមានការងារធ្វើ ហើយអ្នកលែងមានបញ្ហាសុខភាព គឺមានន័យថា អ្នកមានសិទ្ធិទទួលបានអំឡុងពេលសាកល្បងការងារ (TWP, Trial Work Period) ចំនួន 9 ខែ ។ TWP គឺជាអំឡុងពេល 9 ខែ ដែលអនុញ្ញាតឲ្យអ្នកសាកល្បងសមត្ថភាពរបស់អ្នកក្នុងការធ្វើការ ។ អំឡុងពេល 9 ខែនេះ មិនចាំបាច់ត្រូវតែជាប់គ្នាឡើយ តែវាត្រូវស្ថិតក្នុងចិរវេលា “រំកិល” ចំនួន 60 ខែ ។ នៅក្នុងអំឡុងពេល TWP ប្រាក់ចំណូលរបស់អ្នក មិនត្រូវរាប់បញ្ចូល ដើម្បីកាត់បន្ថយប្រាក់ជំនួយ SSDI របស់អ្នកឡើយ

(ក្រមនិយត្តកម្មសហព័ន្ធ 20 [CFR, Code of Federal Regulations] វគ្គទី §404.1592) ។

**<u>សកម្មភាពចំណេញសំខាន់ ៖</u>** សកម្មភាពចំណេញសំខាន់ (SGA, Substantial Gainful Activity) គឺជាការងារដែលអ្នកធ្វើ សម្រាប់យកប្រាក់មកចំណាយ ឬផលចំណេញដែលពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពសំខាន់ចំពោះខួរក្បាល ឬរាងកាយ (20 CFR §404.1572) ។ SGA មានការទាក់ទងទាំងប្រាក់ពលកម្មដែលអ្នកបានទទួលពីការងារ និងប្រាក់កម្រៃរកបានពីមុខរបរផ្ទាល់ខ្លួនរបស់អ្នក ។ SGA ឆ្នាំ2016 មានចំនួន $1,130.00 ក្នុងមួយខែ ចំពោះមនុស្សមិនពិការភ្នែក និងចំនួន $1,820.00 ក្នុងមួយខែ ចំពោះមនុស្សពិការភ្នែក ។ ទាំងនេះគឺជាចំនួនប្រាក់សរុបដុលដែលអ្នករកបានក្នុងមួយខែ ។ គឺមានន័យថាវាជាចំនួនដែលអ្នករកបានមុនការកាត់ថ្លៃពន្ធ ឬការកាត់កងផ្សេងៗទៀតចេញពីសែករបស់អ្នក ។

SSA កំណត់ SGA សម្រាប់មុខរបរផ្ទាល់ខ្លួនជាពីរយ៉ាង ៖

1. ប្រាក់ចំណូលសរុបពីមុខរបរផ្ទាល់ខ្លួន (NESE, Net Earnings from Self-Employment) - NESE គឺជាចំនួនប្រាក់ប្រចាំឆ្នាំដែលអ្នករកបានពីមុខរបររបស់អ្នក ក្រោយពេលកាត់កងរួចរាល់ទៅតាមការអនុញ្ញាតពីការិយាល័យសេវាកម្មចំណូលផ្ទៃក្នុង (IRS, Internal Revenue Service) ។
2. ចំនួនម៉ោងធ្វើការក្នុងមួយខែ – អ្នកបានធ្វើ SGA នៅពេលអ្នកចំណាយពេលចំនួន 80 ម៉ោង ឬច្រើនជាងនេះចំពោះមុខរបររបស់អ្នកក្នុងមួយខែ ។

ចំនួន SGAសម្រាប់មុខរបរផ្ទាល់ខ្លួនគឺ $1,130.00 សម្រាប់មនុស្សមិនពិការភ្នែក និង $1,820.00 សម្រាប់មនុស្សពិការភ្នែក ក្នុងមួយខែ ។

*ខែសាកល្បងការងារ (TWM, Trial Work Month) - ដើម្បីកំណត់អំពីថិរវេលាសាកល្បងការងារ (TWP) ចំនួន 9ខែរបស់អ្នក SSA ពិនិត្យមើលចំនួនប្រាក់ដែលអ្នករកបានក្នុងមួយខែ ដើម្បីកំណត់ថាតើអ្នកបានប្រើថិរវេលាមួយខែនៃ TWP ដែរឬទេ ។ ក្នុងឆ្នាំ 2016 ចំពោះខែណាដែលអ្នករកចំណូលបានចំនួន $810.00 ឬច្រើនជាងនេះ គឺមានន័យថាអ្នកបានប្រើថិរវេលា 1 ខែនៃ TWP 9 ខែ ។

ចំនួនប្រាក់នៃ SGA និង TWP អាចប្តូររាល់ឆ្នាំ ។ ការកើនឡើងនៃសន្ទស្សន៍អ្នកប្រើប្រាស់ (CPI-W, Consumer Price Index) ជាធម្មតា វានាំឲ្យមានការកើនឡើងនូវ SGA និង TWP នាឆ្នាំបន្ទាប់ ។

**ការពន្យារថិរវេលាអំពីភាពមានសិទ្ធិទទួលជំនួយ ៖** ក្រោយពេលដែល TWP ត្រូវបានបញ្ចប់ គឺអ្នកចាប់ផ្តើមចូលក្នុងការពន្យារពេលអំពីភាពមានសិទ្ធិទទួលជំនួយ (EPE, extended period of eligibility) ដែលមានរយៈពេលចំនួន 36 ខែ ។ នេះជាថិរវេលាចំនួន 36 ខែជាប់គ្នា ដែលក្នុងពេលនេះប្រាក់ចំណូលទាំងអស់ត្រូវប្រៀបធៀបជាមួយនឹងកម្រិត SGA ដើម្បីកំណត់ថាតើអ្នកនៅមានសិទ្ធិទទួលប្រាក់ជំនួយ SSDI ដែរឬទេ ។

ខែណាមួយ ក្នុងអំឡុងពេល EPE ដែលប្រាក់ចំណូលដុល ឬប្រាក់ចំណូលសរុបរបស់អ្នកមានបរិមាណស្មើនឹង ឬក្រោម SGA គឺអ្នកនៅបន្តទទួលបានប្រាក់ជំនួយ SSDI ដដែល ។ ប្រសិនបើប្រាក់ចំណូលដុល ឬប្រាក់ចំណូលសរុបរបស់អ្នកមានចំនួនលើសពីចំនួន SGA គឺមានន័យថាអ្នកមិនមានសិទ្ធិទទួលបានប្រាក់ជំនួយ SSDI ឡើយ (20 CFR §404.1592a) ។ អំឡុងពេលនេះ ក៏ត្រូវបានគេហៅផងដែរថាជាអំឡុងពេល “ការកំណត់ភាពមានសិទ្ធិទទួលជំនួយឡើងវិញ” ។

អំឡុងពេលការផ្អាក ៖ ក្នុងខែដំបូង បន្ទាប់ពី TWP ត្រូវបានបញ្ចប់ ដោយប្រាក់ចំណូលរបស់អ្នកមានចំនួនលើសពី SGA នោះអ្នកត្រូវចូលទៅក្នុងខែនៃ “ការផ្អាក” របស់អ្នក ដែលពេលនោះ អត្ថប្រយោជន៍អាចត្រូវបញ្ចប់ (20 CFR §404.316 & §404.325) ។ អ្នកនឹងទទួលបានប្រាក់ជំនួយ SSDI របស់អ្នកក្នុងខែនៃការផ្អាក និងចំនួនពីរខែបន្ទាប់ភ្លាមៗ បន្ទាប់ពីខែនៃការផ្អាក ។ អំឡុងពេលបីខែនេះ ក៏ត្រូវបានគេហៅផងដែរថាជា “អំឡុងពេលអនុគ្រោះ” ដែលបន្ទាប់ពីនោះមក អត្ថប្រយោជន៍នឹងត្រូវបានបញ្ឈប់ ។

**ចំណាយចំពោះពិការភាពពាក់ព័ន្ធនឹងការងារ ៖** ការចំណាយចំពោះពិការភាពពាក់ព័ន្ធនឹងការងារ (IRWE, Impairment Related Work Expense) គឺជាការចំណាយរបស់អ្នកចំពោះទំនិញ ឬសេវាកម្ម ដែលអាចជួយឲ្យអ្នកមានសមត្ថភាពធ្វើការ ។ ការចំណាយទាំងនេះ ត្រូវតែចេញដោយរូបអ្នក ហើយមិនអាចមាននរណាម្នាក់បើកយកប្រាក់សំណងចំពោះការចំណាយទាំងនេះបានឡើយ (សៀវភៅក្រហមស្តីអំពីការជ្រោមជ្រែងការងារ, [Redbook on Employment Supports])

**<u>ជំនួយជាប្រាក់ ៖</u>** ជំនួយជាប្រាក់គឺជាការចំណាយចំពោះទំនិញ ឬសេវាកម្មដែលនិយោជករបស់អ្នកជាអ្នកចេញ ដើម្បីជួយឲ្យអ្នកអាចមានសមត្ថភាពធ្វើការ និងបំពេញភារកិច្ចបាន <u>(សៀវភៅក្រហមស្ដីអំពីការជ្រោមជ្រែងការងារ)</u> ។

**<u>ស្ថានភាពពិសេស ៖</u>** ស្ថានភាពពិសេសគឺជា ការចំណាយលើទំនិញ ឬសេវាកម្មដែលភាគីទីបីជាអ្នកចេញ ដើម្បីជួយឲ្យអ្នកអាចធ្វើការ និង/ឬបំពេញតួនាទីរបស់ខ្លួនបាន  <u>(សៀវភៅក្រហមស្ដីអំពីការជ្រោមជ្រែងការងារ)</u> ។

**<u>ថ្លៃមុខរបរដែលខូចខាត ៖</u>** ថ្លៃមុខរបរដែលខូចខាត គឺជាការជួយជ្រោមជ្រែងដោយមិនគិតថ្លៃចំពោះមុខរបររបស់អ្នក ។  ថ្លៃចំណាយលើការជ្រោមជ្រែងចំពោះរូបអ្នក (ជាម្ចាស់មុខរបរ) ត្រូវបានកាត់ចេញ ដើម្បីកំណត់ថាតើប្រាក់ចំណូលរបស់អ្នកមានចំនួនលើសពី SGA ដែរឬទេ <u>(ការធ្វើឲ្យមុខរបរផ្ទាល់ខ្លួនមានដំណើរការសម្រាប់មនុស្សពិការ, [Making Employment Work for People with Disabilities])</u> ។

**<u>ជំនួយដែលមិនបង់ជាសាច់ប្រាក់ ៖</u>** ជំនួយដែលមិនបង់ជាសាច់ប្រាក់ (Unpaid help) គឺជាជំនួយដែលផ្ដល់ជូនដោយឥតគិតថ្លៃដល់អ្នកដែលជាម្ចាស់មុខរបរដែលជាមនុស្សពិការ ដែលទទួលបានជំនួយ SSDI ដែលអ្នកប្រកបមុខរបរផ្សេងមានបំណងចង់ចៀវ ក្នុងនាមជាការចំណាយលើមុខរបរ/ពលកម្ម ។  ថ្លៃពលកម្មដែលសមរម្យ នៃជំនួយដែលផ្ដល់ឲ្យអ្នក ដែលជាម្ចាស់មុខរបរ ត្រូវបានកាត់កងចេញពីប្រាក់ចំណូលសរុប ដើម្បីកំណត់ SGA <u>(ការធ្វើឲ្យមុខរបរផ្ទាល់ខ្លួនមានដំណើរការសម្រាប់មនុស្សពិការ, [Making Employment Work for People with Disabilities])</u> ។

ស្ថិតក្រោមបទបញ្ញត្តិសន្តិសុខសង្គម ថ្លៃចំណាយទាំងនេះ (IRWE ប្រាក់ជំនួយស្ថានភាពពិសេស ការចំណាយលើការខូចខាតមុខរបរ និងជំនួយមិនបង់ជាសាច់ប្រាក់) មិនត្រូវគិតចូលទេ នៅពេលគណនាប្រាក់ចំណូលរាប់បានប្រចាំខែ  (CI, countable income) របស់អ្នក ។  នៅពេលនោះ ប្រាក់ចំណូលរាប់បានរបស់អ្នកត្រូវយកទៅប្រៀបធៀបជាមួយនឹង SGA ដើម្បីកំណត់ថាតើអ្នកមានសិទ្ធិបន្តទទួលបានប្រាក់ជំនួយ SSDI ដែរឬទេ ។  ត្រង់នេះត្រូវបានគេហៅថា “ការសាកល្បង SGA” ។

**<u>ធានារ៉ាប់រង Medicare ជាបន្ត ៖</u>** ជាមួយនឹងច្រកផ្លូវរបស់ក្រមសំបុត្រសម្រាប់ធ្វើការ និងការលើកកំពស់ប្រាក់ឧបត្ថម្ភការងារ ឆ្នាំ 1999 ដែលហៅថា សំបុត្រ (Ticket to Work and Work Incentive Improvement Act of 1999, The Ticket) ការធានារ៉ាប់រង Medicare ត្រូវបានពន្យារពី 39 ទៅ 93 ខែ ។

នៅក្នុងអំឡុងពេលនេះ អ្នកនឹងនៅបន្តរក្សាបានការធានារ៉ាប់រងមេឌីឃែរផ្នែក ក (Medicare Part A) (ការសម្រាកពេទ្យ) មេឌីឃែរផ្នែកខ (Medicare Part B) (ការទៅជួបពេទ្យ) និងមេឌីឃែរផ្នែកឃ (Medicare Part D) (ថ្នាំតាមវេជ្ជបញ្ជា) របស់អ្នក ។ ការធានារ៉ាប់រង Medicare Part A នឹងនៅបន្តទទួលបានដោយឥតគិតថ្លៃ ។ ទោះជាយ៉ាងណាក៏ដោយ ការធានារ៉ាប់រង Medicare Part B និង D គឺជាជម្រើស ហើយអ្នកត្រូវបង់ថ្លៃបុព្វលាភរ៉ាប់រងប្រចាំខែ ដើម្បីរក្សាការធានារ៉ាប់រងទាំងនេះទុក ។

**<u>កម្មវិធីទិញយក Medicaid ៖</u>** នីតិកម្ម “The Ticket” ក៏ជម្រុញឲ្យរដ្ឋ ត្រូវបង្កើតកម្មវិធី “ទិញយក Medicaid” (Medicaid Buy-in) សម្រាប់អ្នកទទួលអត្ថប្រយោជន៍ SSDI ដែលមានការងារធ្វើផងដែរ ។ កម្មវិធី “ទិញយក” នេះ អនុញ្ញាតឲ្យអ្នកអាចជាវការធានារ៉ាប់រង “MediCal” ដោយការបង់ថ្លៃបុព្វលាភរ៉ាប់រងប្រចាំខែ ។ កម្មវិធី “ទិញយក” Medicaid របស់រដ្ឋ កម្មវិធី 250% ជនពិការកាលីហ្វ័រនីញ៉ាដែលធ្វើការ (250% California Working Disabled-250% CWD) ត្រូវបានអនុវត្តក្នុងខែមេសា ឆ្នាំ 2001 ។

**<u>ការទទួលបានមកវិញយ៉ាងឆាប់រហ័ស ៖</u>** លក្ខ័ណ្ឌនៃការអនុវត្តឡើងវិញជាបន្ទាន់ (EXR, expedited reinstatement) នៃកម្មវិធីលិខិតទៅធ្វើការ អាចជួយអ្នកឲ្យកាន់តែងាយស្រួលក្នុងការទទួលបានមកវិញនូវអត្ថប្រយោជន៍ ។ បើប្រាក់ចំណូលរបស់អ្នកស្ថិតនៅក្រោម SGA ក្រោយពេលបញ្ចប់ EPE អ្នកអាចទទួលបានអត្ថប្រយោជន៍ឡើងវិញ ដោយមិនចាំបាច់ដាក់ពាក្យសុំអត្ថប្រយោជន៍ SSDI របស់អ្នកឡើងវិញឡើយ ។

លក្ខ័ណ្ឌនៃការអនុវត្តឡើងវិញជាបន្ទាន់ អាចជួយឲ្យអ្នកផ្តល់ដំណឹងទៅកាន់ SSA ថា អ្នកឈប់ធ្វើការនៅកម្រិត SGA ទៀតហើយ ហើយត្រូវការទទួលអត្ថប្រយោជន៍ឡើងវិញ ។ អត្ថប្រយោជន៍របស់អ្នកអាចចាប់ផ្តើមឡើងវិញ ក្នុងរយៈពេលប្រហែលពីបី ទៅប្រាំមួយសប្តាហ៍ ។

សម្រាប់ព័ត៍មានបន្ថែមស្តីអំពីកម្មវិធីជ្រោមជ្រែងការងារ/ប្រាក់ឧបត្ថម្ភការងារ SSA អ្នកអាចចូលទស្សនាវីបសៃត៍សន្តិសុខសង្គម តាមអាសយដ្ឋាន www.socialsecurity.gov ឬស្នើសុំសំណៅមួយច្បាប់នៃអត្ថបទបោះពុម្ពផ្សាយរបស់ SSA <u>សៀវភៅក្រហមស្តីអំពីការគាំពារការងារ</u> ។ អ្នកក៏អាចទាក់ទងជាមួយនឹងអ្នកសម្របសម្រួលប្រាក់ឧបត្ថម្ភការងារប្រចាំតំបន់សម្រាប់ SSA (Area Work Incentive Coordinator for SSA) គម្រោងផែនការប្រាក់ឧបត្ថម្ភការងារ និងជំនួយការងារ (Work Incentive Planning and Assistance project)

ក្នុងមូលដ្ឋានរបស់អ្នក ។ អ្នកក៏អាចទាក់ទងជាមួយនឹងកម្មវិធីការការពារ និងការតស៊ូមតិចំពោះអ្នកទទួលជំនួយសន្តិសុខសង្គម (PABSS, Protection and Advocacy for Beneficiaries of Social Security) តាមរយៈទូរស័ព្ទលេខ 800-776-5746 ឬទស្សនាវិបសៃត៍របស់អង្គការ Disability Rights California តាមអាស័យដ្ឋាន www.disabilityrightsca.org ផងដែរ ។

*SSA បានពិនិត្យឡើងវិញនូវអត្ថបទបោះពុម្ពផ្សាយខាងក្រោម ដើម្បីធានាបាន ចំពោះភាពត្រឹមត្រូវផ្នែកបច្ចេកទេសតែប៉ុណ្ណោះ ទោះជាយ៉ាងណាក៏ដោយ យើងមិនត្រូវចាត់ទុកថាវាគឺជាឯកសារផ្លូវការរបស់ SSA ឡើយ ។*

*Disability Rights California បានទទួលមូលនិធិឧបត្ថម្ភពីប្រភពផ្សេងៗគ្នា ដើម្បីបើកមើលបញ្ជីម្ចាស់ជំនួយទាំងអស់ សូមចូលទៅកាន់*
http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html.